ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គលេខាធិការដ្ឋាន

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរងនិងពលទាហានទាំងអស់ សូមគាំទ្រយ៉ាងពេញទំហឹងចំពោះសាលដីកាស្ថាពររបស់តុលាការកំពូល នាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកាត់ទោស "រំលាយគណបក្សសង្គ្រោះជាតិ" និងផ្អាកសកម្មភាពនយោបាយរយៈពេល៥ឆ្នាំ ចំពោះថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិចំនួន១១៨រូប គឺពិតជាស័ក្តិសមទៅនឹងទង្វើក្បត់ជាតិរបស់គណបក្សមួយនេះ ដែលមិនអាចអត់ឱនឲ្យបានឡើយ។

យើងខ្ញុំទាំងអស់គ្នា សូមគាំទ្រចំពោះវិធានការរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបន្តទប់ស្កាត់ឧបាយកលបដិវត្តន៍ពណ៌នៅកម្ពុជា។ ប្តេជ្ញាថែរក្សាការពារសន្តិសុខ សន្តិភាពនិងការអភិវឌ្ឍនៅកម្ពុជា ប្រឆាំងទប់ស្កាត់បក្សនយោបាយនិងក្រុមអ្នកនយោបាយដែលឃុបឃិតនិងបម្រើផលប្រយោជន៍បរទេស។ ប្តេជ្ញាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃកម្ពុជា ប្រឆាំងនិងការជ្រៀតជ្រែកទាំងឡាយរបស់បរទេស។ ប្តេជ្ញាគាំទ្រការអនុវត្តវិធានការច្បាប់ និងការគោរពច្បាប់ក្នុងសង្គមដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរងនិងពលទាហានទាំងអស់ សូមប្រកាសគាំទ្រយ៉ាងឧឡារិកចំពោះសាលដីការរបស់តុលាការកំពូលដែលបានកាត់ទោស "រំលាយគណបក្សសង្គ្រោះជាតិ" សូមគាំទ្រនិងសម្តែងនូវភក្តីភាពយ៉ាងស្មោះស្ម័គ្រចំពោះរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនា-បតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែបានបូជាកម្លាំងកាយ កម្លាំងចិត្តនិងប្រកាន់ភ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុង្គឧត្តម ប្រកបដោយការទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនាប្រទេសជាតិនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា។

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរងនិងពលទាហានទាំងអស់ សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទោសកំហុសនៃទង្វើក្បត់ជាតិរបស់គណបក្សសង្គ្រោះជាតិនិងថ្នាក់ដឹកនាំក៏ដូចជាជនអគតិមួយចំនួន ដែលមានឧបាយកលធ្វើបដិវត្តន៍ពណ៌ ជាហេតុនាំមកនូវសង្គ្រាមវិនាសកម្មនិងគ្រោះមហន្តរាយជាថ្មីម្តងទៀតនៅកម្ពុជាទៀតឡើយ។

សូមអំពាវនាវឲ្យមានការចាត់វិធានការផ្លូវច្បាប់ជាបន្តបន្ទាប់ឲ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋក្នុងគោលបំណងថែរក្សា សន្តិភាព ស្ថេរភាព សណ្តាប់ធ្នាប់សាធារណៈនិងដើម្បីភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

**អគ្គលេខាធិការ**

នាយឧត្តមសេនីយ៍ **សំ ចន្ធាថន**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ : ០២៣ ៨៨៣ ២៧៨ អ៊ីមែល : generalsec@mod.gov.kh